00634930

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

លេខ/No: D427/3/12

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់**
**ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម**
**ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤៥ និងអបជ១៤៦)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 01 / 2011
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ**

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង ធីរិទ្ធ
នួន ជា

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ឡោ ជុនធី

**សហមេធាវីការពារក្តីជនជាប់ចោទ**
ផាត់ ពៅស៊ាង
Diana ELLIS

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៨១៤ ទូរសារ (៨៥៥) ២៣ ២១៩ ៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, Cambodia, PO Box 71, Tel: (855) 23 219 814 Fax: (855) 23 219 841 Web: www.eccc.gov.kh

00634931

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤៥ និងអបជ១៤៦)

លេខ/No: D427/3/12

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
DELAHAIE Annie
Fabienne TRUSSES-NAPROUS
ស៊ីន សុវ៉ន
BEAUDOIN Patrick
GUIRAUD Marie
LYMA NGUYEN
វ៉ែន ពៅ
ជេត វណ្ណលី
DESFORGES Laure
DURAND Isabelle
GAUTRY Francoise
MARTINEAU Christine
Pascal AUBOIN
Ferdinand DJAMMEN- Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
ពេជ អង្គ

សុន អរុណ
Michiel PESTMAN
Victor KOPPE

**<u>សហចៅក្រមស៊ើបអង្កេត</u>**

យូ ប៊ុនឡេង

Siegfried BLUNK

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

00634932



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")[១] ដែលបានដាក់កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ និងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្ដឹងឧទ្ធរណ៍របស់ នួន ជា")[២] ដែលបានដាក់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ បន្ទាប់គ្នា។

**ក. <u>បណ្ដឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានដាក់ជូនដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម</u>៖**

១. មូលដ្ឋានទីមួយលើកឡើងថា ក.ស.ច.ស មានកំហុសនៅក្នុងការសន្និដ្ឋាន នៅក្នុងដីកាដែលត្រូវបានជំទាស់ថា "បញ្ហាថាតើ អ.វ.ត.ក គឺជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមែនបង្កើតជាផលវិបាកអ្វីចំពោះយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនោះទេ"[៣]។ ផ្ទុយទៅវិញ បណ្ដឹងឧទ្ធរណ៍របស់ នួន ជា លើកឡើងថា "អ.វ.ត.ក ដែលជាតុលាការជាតិកម្ពុជាសុទ្ធសាធនោះ ត្រូវតែអនុវត្តច្បាប់ជាតិដែលនៅជាធរមាននៅក្នុងចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៩ ឲ្យបានតឹងរ៉ឹងជាទីបំផុត ដែលរួមទាំងការអនុវត្តរបស់កម្ពុជាចំពោះគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែងផងដែរ*"[៤]។

២. មូលដ្ឋានទីពីរលើកឡើងថា "របបច្បាប់ជាតិជាធរមាន នៅពេលហេតុការណ៍ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបានកើតឡើង មិនបានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ថាជាឧក្រិដ្ឋកម្មនោះទេ"[៥]។

---

[១] បណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1 ("បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")។

[២] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 ("បណ្ដឹងឧទ្ធរណ៍របស់ នួន ជា")។

[៣] បណ្ដឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ២៦ ជើងទំព័រ៨៧។

[៤] បណ្ដឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ២៦។

[៥] បណ្ដឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ២៧។

៣. មូលដ្ឋានទីបីលើកឡើងថា ដីកាដែលត្រូវបានជំទាស់លើកឡើងដោយភ័ន្តច្រឡំថា ច្បាប់ អ.វ.ត.ក ផ្តល់នូវច្បាប់សារធាតុសម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម នៅក្នុងប្រទេសកម្ពុជា[៦]។

៤. មូលដ្ឋានទីបួនលើកឡើងថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិដែលត្រូវបានរកឃើញនៅក្នុង "មាត្រា ៣៣(២) នៃច្បាប់ អ.វ.ត.ក ដែលចែងយោងលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ មិនបានធ្វើឲ្យបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ក្លាយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាឡើយ ពីព្រោះតែបទល្មើសអន្តរជាតិទាំងនេះ មិនអាចអនុវត្តបានឡើយនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩"[៧]។

៥. មូលដ្ឋានទីប្រាំអះអាងថា ទោះបីជា "ច្បាប់ អ.វ.ត.ក បានកំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់មាត្រា ៦ ថាជាបទល្មើសព្រហ្មទណ្ឌ ច្បាប់ធ្វើឡើងតាមអានុភាពប្រតិសកម្មបែបនេះ រំលោភលើគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជា"[៨]។

**ខ. <u>បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានដាក់ជូន ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម</u>៖**

៦. មូលដ្ឋានទីមួយលើកឡើងថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មិនអាចត្រូវបានកាត់សេចក្តីនោះទេ ពីព្រោះបទល្មើសទាំងអស់នេះ មិនមែនជាបទឧក្រិដ្ឋនោះទេ តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នៅពេលដែលបទល្មើសដែលបានចោទប្រកាន់ទាំងនោះ ត្រូវបានប្រព្រឹត្ត[៩]។

៧. មូលដ្ឋានទីពីរលើកឡើងថា ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

---

[៦] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ៣០ ដល់៣២។

[៧] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ៣៣។

[៨] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ៣៥។

[៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ១៦, ១៧, ៤២, ៤៣, ៦៧ និង៦៨។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[១០] ក.ស.ច.ស "បានធ្វើការបកស្រាយមិនត្រឹមត្រូវតាមរបៀបដែលថា ច្បាប់ អ.វ.ត.ក មានបំណងបង្កើតច្បាប់ព្រហ្មទណ្ឌថ្មី និងអនុវត្តច្បាប់នោះ ឲ្យមានប្រតិសកម្មទៅលើអំពើដែលរងការចោទប្រកាន់ថា ត្រូវបានប្រព្រឹត្តកាលពី៣០ឆ្នាំមុន"[១១]។

៨. មូលដ្ឋានទីបីលើកនូវទឡ្ហីករណ៍ជាច្រើនដែលអះអាងថា ក្រោមច្បាប់អន្តរជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មិនអាចអនុវត្តផ្ទាល់នៅ អ.វ.ត.ក ទេ ហេតុដូច្នេះហើយ អៀង ធីរិទ្ធ មិនអាចទទួលការកាត់សេចក្តី ផ្អែកតាមមូលដ្ឋានទាំងអស់នេះទេ[១២]។

៩. មូលដ្ឋានទីបួនលើកឡើងថា ក.ស.ច.ស មានកំហុសនៅក្នុងការយល់ឃើញថា អៀង ធីរិទ្ធ បានដឹងជាមុនថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ និងដឹងជាមុនថាទង្វើទាំងនេះអាចនឹងត្រូវផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[១៣]។

១០. មូលដ្ឋានទីប្រាំលើកឡើងថា ក.ស.ច.ស មានកំហុសនៅក្នុងការយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មជាតិ ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[១៤] ពីព្រោះការពន្យារពេលនៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់នេះ រយៈពេល៣០ឆ្នាំថែមទៀត ស្របតាមមាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ "ចាត់ទុកថាជា

---

[១០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ១៨ ដល់២១, ៤៤ ដល់៤៥ និង៧០។

[១១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ១៩។

[១២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ២២ ដល់៣៧, ៤៦ ដល់៥៧, ៧១ ដល់៧២។

[១៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣៥ ដល់៣៧, ៥៨ ដល់៦៣។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីជាទឡ្ហីករណ៍ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់នេះ ត្រូវបានលើកឡើងក្រោមមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ទឡ្ហីករណ៍ទាំងនោះពិតជាមានការពាក់ព័ន្ធទៅនឹងមូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងនូវទឡ្ហីករណ៍ដូចគ្នាទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ដូចនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាលើទឡ្ហីករណ៍ទាំងនោះរួមគ្នា ក្រោមមូលដ្ឋានទីបួន។

[១៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៧៣ ដល់៧៩។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ការបំពានលើគោលការណ៍ទូទៅស្តីពី *គ្មានបទល្មើសបើគ្មានច្បាប់ចែង*[១៥] និង "ជាការបំពានលើគោលការណ៍ទូទៅស្តីពីសិទ្ធិស្មើភាពគ្នាក្នុងរឿងក្តីដូចគ្នា"[១៦]។

១១. មូលដ្ឋានទីប្រាំមួយអះអាងថា ដីកាដែលត្រូវបានជំទាស់មានកំហុសនៅក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួម ធ្វើជាគំរូនៃការទទួលខុសត្រូវរបស់បុគ្គល។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែអង្គបុរេជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ អៀង ធីរិទ្ធ មានចេតនា "ជំទាស់ការអនុវត្តទ្រឹស្តីនេះនៅក្នុងសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយមិនទាន់ជំទាស់ក្នុងបណ្តឹងឧទ្ធរណ៍នៅពេលនេះទេ"[១៧]។

១២. មូលដ្ឋានទីប្រាំពីរអះអាងថា ដីកាដែលត្រូវបានជំទាស់មានកំហុសនៅក្នុងការអនុវត្ត "ការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវដែលទាក់ទងទៅនឹងបទឧក្រិដ្ឋកម្មបី ដែលកំណត់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[១៨] ។ ដោយសារតែ "គ្មានមូលដ្ឋានទំនៀមទម្លាប់ដែលគាំទ្រការអនុវត្តទ្រឹស្តីនេះទេ ក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" ការកាត់សេចក្តីលើការទទួលខុសត្រូវរបស់ថ្នាក់លើ ជាការរំលោភបំពានលើគោលការណ៍ដែលថា *គ្មានបទល្មើស បើគ្មានច្បាប់ចែង*[១៩]។ ឬក៏ជាជម្រើសមួយផ្សេងវិញ ការទទួលខុសត្រូវរបស់ថ្នាក់លើ "អាចត្រូវបានគេយកមកចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ"[២០]។ ជាងនេះទៅទៀត "ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ គឺផ្អែកលើមូលដ្ឋាននៃការខកខានមិនបានចាត់វិធានការ" និង "ដីកាដំណោះស្រាយខកខានមិនបានបង្ហាញអំពីកាតព្វកិច្ចបែបនេះ"[២១]។

១៣. មូលដ្ឋានទីប្រាំបីលើកឡើងថា ដីកាដែលត្រូវបានជំទាស់ "មិនរវីរវល់ទៅនឹងការរកឃើញអង្គច្បាប់

[១៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៧៧។

[១៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៧៨។

[១៧] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៨០។

[១៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៨១។

[១៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៨៤។

[២០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩០។

[២១] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩៣។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដទៃៗទៀតឡើយ” ពីព្រោះ ក.ស.ច.ស ខកខានមិនបានផ្តល់មូលដ្ឋានភស្តុតាងដោយមានសំអាងហេតុ ដើម្បីគាំទ្រលើសេចក្តីសម្រេចរបស់ខ្លួនឡើយ”[២២]។

១៤. មូលដ្ឋានទីប្រាំបួនលើកឡើងថា ក.ស.ច.ស “មានការភ័ន្តច្រឡំនៅពេលខកខានមិនបានយកអង្គហេតុជាក់លាក់នៅក្នុងរឿងក្តី ... មកអនុវត្តចំពោះបញ្ហាទាំងឡាយដែលត្រូវសម្រេចឡើយ” និង “គ្រាន់តែបានយោងលើការរកឃើញអង្គហេតុ ដែលទទួលស្គាល់រួចហើយដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ឌុច តែប៉ុណ្ណោះ” ដោយគ្មានការលើកហេតុផលសមរម្យឡើយ[២៣]។

១៥. មូលដ្ឋានទីដប់លើកឡើងថា កថាខណ្ឌ ១៥៧៤ នៃដីកាដំណោះស្រាយ “ត្រង់ផ្នែកដែលទាក់ទិននឹងការចោទប្រកាន់បញ្ជូនដើមបណ្តឹងឧទ្ធរណ៍ទៅជំនុំជម្រះពីបទល្មើសទាំងឡាយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រូវចាត់ទុកជាមោឃៈ”[២៤] ពីព្រោះវា “ខកខានមិនបានចែងអំពីការកំណត់បទល្មើសដោយផ្អែកលើអង្គហេតុឡើយ”[២៥] ដែលចាំបាច់ដើម្បីឲ្យដើមបណ្តឹងឧទ្ធរណ៍អាចរៀបចំការការពារខ្លួន “និងដើម្បីជៀសវាងហេតុការណ៍ដែលប៉ះពាល់ដល់ខ្លួនជាយថាហេតុ”[២៦]។

អង្គបុរេជំនុំជម្រះបានសម្រេចជាស្ថាពរលើបណ្តឹងឧទ្ធរណ៍ ដូចដែលអង្គបុរេជំនុំជម្រះប្រកាសនៅពេលនេះ។ ការចេញសំអាងហេតុសម្រាប់គាំទ្រសាលដីកានេះ នឹងធ្វើទៅតាមពេលវេលាសម ស្រប។

PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

[២២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩៧។

[២៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩៨។

[២៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩៩។

[២៥] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ១០០។

[២៦] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ១០១។

**អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ដូចខាងក្រោម៖**

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន និងទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំ (ផ្នែកខ្លះ) និងទីប្រាំពីរ (ផ្នែកខ្លះ) នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចទទួលយកបាន។ មូលដ្ឋានដែលនៅសេសសល់ដទៃទៀតនៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ។ ភាពមិនអាចទទួលយកបាននៃអនុមូលដ្ឋានទីប្រាំ និងទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ មានដូចជា៖

- មូលដ្ឋានទីប្រាំ ដែលបានលើកឡើងថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាក់អះអាងអំពីយុត្តាធិការ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាតិដែលត្រូវបានចោទប្រកាន់តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជាការរំលោភលើសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់ អៀង ធីរិទ្ធ។

- មូលដ្ឋានទីប្រាំពីរ ដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការជជែកវែកញែកឱ្យបានត្រឹមត្រូវថាជាបញ្ហាអង្គហេតុអត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ដែលត្រូវបំពេញ និងមូលដ្ឋាននៅក្នុងច្បាប់ជាតិជាធាតុផ្សំមួយនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

៣. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៧. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៨. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៩. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១០. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១១. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានអនុញ្ញាតផ្នែកខ្លះដូចខាងក្រោម រីឯផ្នែកផ្សេងទៀតត្រូវបានបដិសេធ។

១- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតដរាបណាសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានមិនបានធ្វើការពិចារណាថា នៅក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានតម្រូវឱ្យមានចំណងពាក់ព័ន្ធគ្នារវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវបានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងផ្នែកទីIV(ក) ជំពូកបី នៃដីកាដំណោះស្រាយ។

២- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតដរាបណាសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

១២. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

00634939



១៣. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

១៤. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១៥. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឲ្យបញ្ជូនខ្លួនជំនុំជម្រះដូចដែលបានចែងនៅក្នុងដីកាដំណោះស្រាយ ដែលត្រូវអានព្រមគ្នាជាមួយនឹងសាលដីកានេះ។

១៦. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នត្រូវបានបង្គាប់ឲ្យបន្តចិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING ណី ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន**